# ការប្រមូលទិន្នន័យអំពីអំពើហិង្សាលើស្ត្រី និង ជំងឺកូវីដ-១៩៖ មែកធាងនៃការធ្វើសេចក្ដីសម្រេចចិត្ត

WHO kNOwVAWdata UNFPA UN WOMEN

**ហេតុអ្វី បានជាអ្នកចង់ប្រមូលទិន្នន័យនេះ ហើយអ្នក នឹងប្រើប្រាស់ទិន្នន័យនេះដោយរបៀបណា? តើមានសំណួរអ្វីខ្លះដែលមានសារៈសំខាន់សម្រាប់ការស្វែងរកទិន្នន័យ?**

**សំណួរគន្លឹះដែលអាចប្រើប្រាស់សម្រាប់ការស្ទង់មតិផ្អែកលើចំនួនប្រជាជន៖**

- តើអំពើហិង្សា មានការកើនឡើងដែរឬទេ?
- តើធម្មជាតិ ទម្រង់ និងភាពធ្ងន់ធ្ងរ នៃអំពើហិង្សា មានការប្រែប្រួលដែរឬទេ?
- តើកត្តាហានិភ័យ/កត្តានៃការការពារ នៃអំពើហិង្សា មានការប្រែប្រួលដែរឬទេ?

**សំណួរគន្លឹះដែលអាចប្រមូលបានពីប្រភពទិន្នន័យផ្សេងៗទៀត៖**

- តើមានការប្រែប្រួលចំពោះធម្មជាតិ ទម្រង់ និងភាពធ្ងន់ធ្ងរ នៃអំពីហិង្សាដែលគេបានរាយការណ៍ ដែរឬទេ?
- តើមានការកើនឡើង ឬថយចុះ ចំពោះការប្រើប្រាស់សេវាដែរឬទេ?
- តើសេវាអាចប្រើប្រាស់បានឬទេ?និង/ឬការផ្ដល់សេវាមាន ភាពខុសៗគ្នាដែរឬទេ ហើយតើ វាមានសុវត្ថិភាព និងមាន ប្រសិទ្ធភាពដែរឬទេ?

តើ មានការបិទប្រទេសដែរឬទេ ឬ តើមានការហាមប្រាមក្នុងការធ្វើដំណើរយ៉ាងតឹងរឹងដែរឬទេ?

មិនមាន

តើអ្នក អាចធានាថាមានភាពសម្ងាត់ មានឯកជនភាពនិងមានការគាំទ្របានដែរឬទេ?

មិនអាច

អាច

មានសុវត្ថិភាពក្នុងការប្រមូលទិន្នន័យតាមរយៈការស្ទង់មតិឬសម្ភាសន៍អំពីអំពើហិង្សា។

**សំខាន់!**

ទិន្នន័យតំណាង អំពីចំនួនស្ត្រីដែលជួបប្រទះអំពើហិង្សា (ស្ថានភាពទូទៅ) មុន កំឡុងពេល និងក្រោយពេលមានជំងឺកូវីដ១៩ អាចប្រមូលបានតែតាមរយៈការស្ទង់មតិដោយមានសំណាកស្ត្រីតាមការជ្រើសរើសដោយចៃដន្យ តែប៉ុណ្ណោះ។

មាន

កុំធ្វើ

អ្នកសម្ភាសន៍ មិនអាចទៅដល់ផ្ទះគេ និងរៀបចំសម្ភាសន៍ដោយសម្ងាត់និងជាលក្ខណៈឯកជនប្រកបដោយសុវត្ថិភាពឡើយ

តើទិន្នន័យដែលមានស្រាប់ បានឆ្លើយនឹងសំណួរដែលគេតែងតែចោទសួរដែរឬទេ?

ប្រើ

**ប្រើប្រាស់ទិន្នន័យដែលមានស្រាប់!**

- ស្វែងរកទិន្នន័យពីការសិក្សាស្ទង់មតិដែលមានស្រាប់។
- វិភាគកំណត់ត្រាករណីអំពីសេវា (នៅមុននិងកំឡុងពេលមានជំងឺកូវីដ១៩)។

មិនប្រើ

**ជម្រើសក្នុងការស្រាវជ្រាវជាគោល ដែលមានសុវត្ថិភាព និងដែលអាចផ្ដល់ព័ត៌មានពាក់ព័ន្ធបាន៖**

- **ផែនទីសេវា** រួមមានការប្រែប្រួលនៃទិន្នន័យដែលមាន និងធនធាននានា។
- **ធ្វើការស្ទង់មតិខ្លីៗ ឬសម្ភាសន៍អ្នកផ្ដល់ព័ត៌មានចម្បងៗ** សម្ភាសជាមួយអ្នកផ្ដល់សេវានានា។
- **សម្ភាសន៍ជនរងគ្រោះ ប្រសិនបើអាចធ្វើបានប្រកបដោយសុវត្ថិភាព និងមានការយល់ព្រមពេញលេញ** (ឧទាហរណ៍៖ នៅក្នុងអង្គការ មណ្ឌលសុខភាព ឬមណ្ឌលស្នាក់នៅរបស់ស្ត្រី)។

តើ ខ្ញុំអាចប្រើទិន្នន័យអំពីសេវា ដើម្បីកំណត់អំពីស្ថានភាពទូទៅបានឬទេ? (ឧទាហរណ៍៖ របាយការណ៍ប៉ូលីស ការហៅទូរស័ព្ទមកប្រព័ន្ធផ្ដល់ជំនួយ ទិន្នន័យពីមណ្ឌលស្នាក់នៅ)?

កុំប្រើ

**ទេ។** មានស្ត្រីរងគ្រោះមួយចំនួនតូចតែប៉ុណ្ណោះ ដែលប្រើសេវា។ យើង មិនអាចបកស្រាយថាការប្រែប្រួលនៃទិន្នន័យអំពីការប្រើសេវា ថាជាការប្រែប្រួលនៃស្ថានភាពទូទៅបានទេ។
ទិន្នន័យអំពីសេវា មានសារៈសំខាន់ក្នុងការឆ្លើយសំណួរផ្សេងៗគ្នា។

តើខ្ញុំ អាចបន្ថែមសំណួរមួយចំនួនអំពីបទពិសោធន៍នៃអំពើហិង្សា ទៅក្នុងការស្ទង់មតិផ្អែកលើចំនួនប្រជាជនដែលធ្វើការប៉ាន់ប្រមាណភ្លាមៗ អំពីផលប៉ះពាល់នៃជំងឺកូវីដ១៩ បានដែរឬទេ?

តើខ្ញុំ អាចធ្វើការសម្ភាសន៍តាមទូរស័ព្ទ ឬប្រមូលទិន្នន័យដោយប្រើប្រព័ន្ធអ៊ីនធឺណែត/ទូរស័ព្ទដៃដើម្បីទទួលបានទិន្នន័យអំពីស្ថានភាពទូទៅនៃអំពើហិង្សា បានដែរឬទេ?

កុំធ្វើ

**ទេ។** ការចូលរួមរបស់ស្ត្រីនៅក្នុងការស្ទង់មតិនីមួយៗអំពីអំពើហិង្សា ជាពិសេសនៅពេលនៅផ្ទះជាមួយជនប្រព្រឹត្តអំពើហិង្សា អាចបណ្ដាលឲ្យមានអំពើហិង្សាកាន់តែច្រើន និង/ឬ អាចបណ្ដាលឲ្យទទួលបានទិន្នន័យដែលមិនមានគុណភាព។

តើវា នឹងមានសារៈប្រយោជន៍ទេក្នុងការបន្ថែមសំណួរតាមការព្យាករណ៍ទូទៅ ទៅក្នុងការប៉ាន់ប្រមាណភ្លាមៗ (ឧទាហរណ៍៖ អំពើហិង្សាដែលអ្នកផ្សេងជួបប្រទះ) ដែរឬទេ?

កុំបន្ថែម

**ទេ។** យើង នឹងមិនដឹងអំពីអ្វីដែលគេ ប្រាប់យើងឡើយ។ វា មិនអាចយកមកចាត់វិធានការបានទេ។

**ត្រូវផ្ដល់អាទិភាពចំពោះសុវត្ថិភាពរបស់ស្ត្រីជាចម្បងគ្រប់ពេលវេលា ជាជាងការប្រមូលទិន្នន័យ!**

*សូមចូលមើលព័ត៌មានសង្ខេបដែលភ្ជាប់មកជាមួយសម្រាប់ព័ត៌មានលម្អិត (នាពេលឆាប់ៗខាងមុខ!)*

*v. ៣០ មិថុនា ២០២០*